កាលបរិច្ឆេទៈ ថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៨

# មេរៀនដំណាំផ្ទី(ស)

## បច្ចេកទេសនៃការដាំដំណាំផ្ទីស

### ១.ការរៀបចំដី

- ភ្ជួរដីហាលដីរយៈពេលពី៧-១៥ថ្ងៃ
- ត្រូវភ្ជួររាស់ដីឱ្យបាន២ទៅ៣ដងក្នុងជម្រៅពី២ទៅ៣តឹក។

### ២.ការរៀបចំរងឬថ្នាល

☺ ធ្វើរងទទឹងយកប្រវែង១ម៉ែត្រ បណ្តោយតាមលទ្ធភាពដី

☺ ត្រូវលើកកំពស់រងពី១០-២៥ស.ម បណ្តោយរងប្រវែង១០ម៉ែត្រ

☺ ចន្លោះពីរងមួយទៅរងមួយយកប្រវែងពី២,៥តឹក-៣តឹក

☺ ត្រូវប្រើជីធម្មជាតិឬជីកំប៉ុស្តិ៍សម្រាប់ទ្រាប់បាតចំនួន២០-២៥បង្គី។

### ៣.ការដាំដុះ

- ត្រូវធ្វើដីរងឬថ្នាលឱ្យបានស្អាតល្អ និងច្របល់ជីធម្មជាតិជាមួយដីរងឱ្យបានសព្វល្អ។

- យកគ្រាប់ពូជផ្ទីមកហាលថ្ងៃរយៈពេលពី៣០ទៅ៥០នាទី
- យកគ្រាប់ពូជត្រាំទឹករយៈពេលពី២ទៅ៣ម៉ោង រួចផ្អាប់១យប់
- យកខ្សាច់៤ភាគច្របល់ជាមួយគ្រាប់ពូជឱ្យបានសព្វល្អ បន្ទាប់មកយកវាទៅព្រោះលើថ្នាលស្តើងៗល្មម។
- រោយអំពុកចំបើង(បើមាន) រួចហើយស្រោចទឹកឱ្យជាគ។

- **ករណីមួយទៀត៖**

➢ គ្រាប់ពូជមិនចាំបាច់ត្រាំទឹកទេ បន្ទាប់ពីហាលថ្ងៃរួចអាចយកវាទៅព្រោះបាន។

➢ គ្រាប់ពូជចាប់ផ្តើមដុះពន្លកក្រោយពីព្រោះបាន៣ទៅ៥ថ្ងៃ

➢ នៅពេលកូនផ្ទីដុះបានពី៧ទៅ១០ថ្ងៃ អាចដកយកទៅស្ទូងឬដូសបានឬកំពស់២ថ្នាំងដៃ ដោយចន្លោះពីគុម្ពមួយទៅគុម្ពមួយប្រវែង១ទៅ២តឹកឬ២ទៅ៣តឹក។

## ៤.ការថែទាំ

☺ ត្រូវស្រោចទឹកឱ្យបានសមស្រប កុំជោគជាំពេកបណ្តាលឱ្យរលួយ

☺ ត្រូវជ្រុំជើងឱ្យបានល្អ

☺ បោចស្មៅ មើលសត្វល្អិតនិងដាក់ជី។

រៀបចំដោយ លោក យុគ សឿង នាយករងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអាវ៍ឌីណាស់ (CRDNASE)

## ៥.ការប្រមូលផល

➢ ការប្រមូលផលធ្វើឡើងនៅពេលដំណាំផ្ទីអាយុបាន២៥ទៅ៣០ថ្ងៃ

➢ អាចដកទាំងឫស ឬកាត់ស្លឹកត្រួយ ការកាត់ត្រួយអាចប្រមូលបានច្រើនលើក វាអាស្រ័យតាមទីផ្សារ។

## ៦.ការរក្សាពូជ

✓ ត្រូវទុកដើមឱ្យវាចេញផ្កាផ្លែ។ លុះផ្លែទុំល្អមហើយគេបូតវាដាក់ថង់ ហើយហាលថ្ងៃឱ្យស្ងួត។

✓ ញីឱ្យខ្ទេចរួចរោយយកគ្រាប់វារួចយកទៅហាលថ្ងៃម្តងទៀត រួចប្រចកដកទុកដាំដុះឆ្នាំក្រោយ។

**សូមអរគុណ**

កាលបរិច្ឆេទ: ថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៨

# មេរៀនដាំពពាយ

## បច្ចេកទេសនៃការដាំដំណាំពពាយ

### ១.ការរៀបចំដី

- ភ្ជួរដីហាលដីរយៈពេលពី៧-១០ថ្ងៃ
- ត្រូវភ្ជួររាស់ប្រែដីឱ្យបាន២ទៅ៣ដងក្នុងជម្រៅពី២ទៅ៣តឹក។

### ២.ការលើករង

☺ ត្រូវលើករងទទឹងប្រវែង១ម៉ែត្រ ឬកន្លះម៉ែត្រ តាមការដាំដុះ រីឯបណ្ដោយរងតាមលទ្ធភាព។

☺ ត្រូវលើកកំពស់រងពី២០-៣០ស.ម

☺ ចន្លោះពីរងមួយទៅរងមួយអាចយកប្រវែង៣តឹក

### ៣.ការដាំដុះ

**ក)ការដាំ១ជួរ៖** ការដាំ១ជួរគឺត្រូវធ្វើរងទទឹងប្រវែងកន្លះម៉ែត្រ ហើយគម្លាតពីគុម្ពមួយទៅគុម្ពប្រវែងពី៥ទៅ៧តឹក រីឯរណ្ដៅយកប្រវែង២តឹកបួនជ្រុង។ លើសពីនោះយើងប្រើដី១គីឡូក្រាមសម្រាប់១រណ្ដៅ។

រៀបចំដោយ លោក យុគ សឿង នាយករងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)
កែសម្រួលអត្ថបទដោយ ស៊ុន សុគន្ធី មន្ត្រីគម្រោងរបស់អង្គការស៊ីអារ៍ឌីណាស់ (CRDNASE)

## ៩)ការដាំ២ជួរ

ការដាំ២ជួរគឺត្រូវធ្វើរងទទឹងប្រវែងមួយម៉ែត្រ ហើយគម្លាតពីគុម្ពមួយទៅគុម្ពប្រវែងពី៥ទៅ៧តឹក ទ្រូងកណ្ដាលយកប្រវែង៣តឹក។ ការដាំគឺមានលក្ខណៈជាអក្សរវី(V) ដោយក្នុង១រណ្ដៅយើងប្រើពូជ២គ្រាប់។ យើងត្រូវយកគ្រាប់ពូជហាលថ្ងៃរយៈពេល១ទៅ២ម៉ោង បន្ទាប់មកយកគ្រាប់ពូជនោះត្រាំទឹករយៈពេលពី៣ទៅ៤ម៉ោងហើយផ្អាប់វា១យប់ទើបយកទៅដាំ។

## ៤.ការដាក់ទ្រើង

- សម្រាប់ការដាំជា២ជួរគឺគេអាចដាក់ខ្វែងគ្នាដូចទ្រើងសណ្ដែកក៏បាន
- សម្រាប់ការដាំ១ជួរគឺគេធ្វើជាចំណារដូចជាទ្រើងននោង ត្រឡាចឬដាក់សម្រាសឱ្យឡើងដើមឈើក៏បាន។
- គេអាចដាក់ទ្រើងឱ្យពញាយឡើងនៅពេលវាដុះបានប្រវែង២តឹក។

## ៥.ការថែទាំ

- ☺ ត្រូវស្រោចទឹកឱ្យបានគ្រប់គ្រាន
- ☺ បោចស្មៅ មើលសត្វល្អិតនិងដាក់ជីបំប៉ន។

## ៦.ការប្រមូលផល

- ដំណាំពពាយយើងអាចប្រមូលផលបាននៅពេលវាអាយុចាប់ពី៤៥ ទៅ៥០ថ្ងៃ។
- ចំពោះពពាយបុរាណវិញគឺចាប់ពី៣ខែទៅ៦ខែ ទើបអាចប្រមូលផលបាន។
- បើថែទាំបានល្អ ពពាយអាចរស់នៅបានរយៈពេល២ឆ្នាំឬលើសជាងនេះ។

## ៧.ការរក្សាពូជ

- ✓ យើងអាចរក្សាពូជទុកបានលុះត្រាតែពូជនោះមិនមែនជាពូជបង្កាត់
- ✓ ការទុកពូជត្រូវមើលផ្លែណាដែលល្អ មិនជាប់ដី កុំទុកឱ្យទុំហួសពេក
- ✓ យកផ្លែពូជហាលថ្ងៃរួចបកយកគ្រាប់ចេញ បន្ទាប់មកយកវាហាលថ្ងៃម្តងទៀតឱ្យស្ងួត។
- ✓ យកគ្រាប់ពូជហាលថ្ងៃស្ងួតនោះមកទុកក្នុងដបគ្របឱ្យជិត
- ✓ មួយទៀតយើងអាចទុកវាទាំងផ្លែក៏បានឱ្យតែកុំឱ្យខ្មូតស៊ី៕

**សូមអរគុណ**